**Local Control and Accountability Plan (LCAP)**
**គម្រោងការណ៍គ្រប់គ្រង និង ទទួលខុសត្រូវប្រចាំតំបន់**

សំនួរ ដែលតែងតែលើកសួរ – ថ្ងៃទី17 ខែមិថុនា ឆ្នាំ2014

www.lbschools.net/lcap

*តទៅនេះ គឺជាសេចក្តីសង្ខេបអំពីការពិគ្រោះដោះស្រាយ ប្រាំ ចំណែកសំខាន់ជាងគេ ដែលបានទទួលការលើកសួរជាញឹកញាប់នៅក្នុងរយៈពេលបង្កើតគម្រោងការណ៍ LCAP ។*

## សេចក្តីសង្ខេបនៃគម្រោងការណ៍

គម្រោងការណ៍ LCAP មាន បី ចំណុចសំខាន់:

- *Section 1 – ទំនាក់ទំនងជាមួយបុគ្គល ដែលមានមុខងារក្នុងកម្មវិធីសិក្សា* ដូចតាមការរៀបរាប់នៅក្នុងការប្រឹងប្រែងនៃក្រសួងអប់រំ ឱស្រ្ទីគ LBUSD ដែលរាប់បញ្ចូលមតិសាធារណៈទៅក្នុងគម្រោងការណ៍ ។ ដំណើរការពេញឆ្នាំនេះ គឺរាប់បញ្ចូលការស្ទង់មតិទូទាំងក្រសួងអប់រំ ឱស្រ្ទីគ ដែលបានទទួលមកវិញជាង 13,800 ចម្លើយ, សមាជិកគ្រប់ឋានៈចំនួន 66 នាក់នៅក្នុងក្រុមប្រឹក្សា LCAP ដែលបានលើកបង្ហាញរួមគ្នាអំពី 15 អនុសាសន៍ និង កម្មវិធីប្រជុំជាបន្តបន្ទាប់ជាមួយបុគ្គលទាំងអស់ ដែលមានមុខងារក្នុងកម្មវិធីសិក្សា ដើម្បីបង្កើតជាគោលយោបល់ស្របគ្នាសំរាប់គម្រោងការណ៍ ។

- *Section 2 – គោលដៅ និង សញ្ញាបង្ហាញភាពលូតលាស់* គឺប្រើសំរាប់បង្កើតរង្វាស់ជោគជ័យនៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ LBUSD ។ វាកើតឡើងតាមរយៈប្រើគម្រោងការណ៍ចាត់ចែងសំខាន់, ច្បាប់ Academic and Career Success Initiative, កិច្ចសន្យា Long Beach College Promise, ការលើកលែងក្រោមច្បាប់ No Child Left Behind និង កម្មវិធីផ្សេងៗប្រចាំតំបន់ ។

- *Section 3 – កិច្ចការរៀបចំធ្វើ, ជំនួយទូទៅ និង ការចំណាយផ្សេងៗ* គឺលើកពិគ្រោះអំពីកម្មវិធីផ្សេងៗរបស់ក្រសួងអប់រំ ឱស្រ្ទីគ LBUSD ដែលគាំទ្រមកកាន់សាលារៀន, សិស្ស និង ក្រុមគ្រួសារ, ជាពិសេស:

    A. ការប្រើរូបមន្តថ្មីសំរាប់ចាត់ចែងថវិការ ដែលប្រើជុំវិញមកលើជំនួយទូទៅសំរាប់សិស្សទាំងអស់ – ឧទាហរណ៍: ការចំណាយចាំបាច់ទូទៅជាងគេ ដែលត្រូវការសំរាប់រៀបចំប្រព័ន្ធសាលារៀន ។

    B. ការប្រើជំនួយ Supplemental និង Concentration Grants ស្ថិតនៅក្រោមការគ្រប់គ្រងរូបមន្តចាត់ចែងថវិការថ្មី ដែលសំដៅមកលើការរៀបចំទូទៅ, ជាពិសេស គឺជួយសិស្សមកពីក្រុមគ្រួសារមានប្រាក់ចំណូលតិច, សិស្សចាត់ទុកឡើងវិញជាសិស្សមានសមត្ថភាពប្រើភាសា អង់គ្លេស ស្ទាត់ និង សិស្ស ដែលត្រូវបានមនុស្សធំផ្សេងជ្រើសយកចិញ្ចឹម ។

    C. ចំណុចនេះផ្តល់ពត៌មានបន្ថែមអំពីជំនួយ Supplemental និង Concentration Grants ដោយរៀបរាប់សេចក្តីសង្ខេបអំពីគម្រោងការណ៍ទូទៅនៅតាមក្រសួងអប់រំ ឱស្រ្ទីគ ទាំងមូល និង សាលារៀនទាំងមូល ។ ដើម្បីបង្កើនទឹកចិត្តនៃការគ្រប់គ្រងប្រចាំតំបន់ គឺក្រសួងអប់រំ ឱស្រ្ទីគ ឡុង ប៊ីច ប្រឹងប្រែងចែកផ្តល់ជំនួយផ្សេងៗទៅកាន់សាលារៀន, ជាពិសេស គឺសំដៅជួយសាលារៀនទាំងឡាយណា ដែលត្រូវការជំនួយខ្លាំងជាងគេ ដោយមូលហេតុថា សហគមន៍សាលារៀនអាចដោះស្រាយសេចក្តីត្រូវការពិសេសផ្សេងៗបានសំរាប់ជួយសិស្សរបស់ពួកគេរៀងៗខ្លួន ។

    D. ចំណុចនេះពន្យល់អំពីគម្រោងការណ៍ ដែលក្រសួងអប់រំ ឱស្រ្ទីគ LBUSD នឹងបង្កើនជំនួយសំរាប់ជួយសិស្សមកពីក្រុមគ្រួសារមានប្រាក់ចំណូលតិច, សិស្សរៀនភាសា អង់គ្លេស, សិស្សទទួលការចាត់ទុកឡើងវិញជាសិស្សមានសមត្ថភាពប្រើភាសា អង់គ្លេស ស្ទាត់ និង សិស្ស ដែលត្រូវបានមនុស្សធំផ្សេងជ្រើសយកចិញ្ចឹម ។ គម្រោងការណ៍ គឺរាប់បញ្ចូលទាំងការកែប្រែមេរៀនបង្ហាត់ទាំងស្រុងសំរាប់សិស្សរៀនភាសា អង់គ្លេស ដើម្បីតម្រូវតាមការប្រើមេរៀនបង្ហាត់

long beach unified school district

ស្រដៀងគ្នាថ្មីហៅថា Common Core, បង្កើនមធ្យោបាយសំរាប់ឃ្លាំមើលភាពលូតលាស់នៃសិស្ស និង បង្កើតដៃគូជាមួយក្រសួងផ្សេងៗសំរាប់ទាមទារការប្រុងប្រៀបសិស្សទៅរៀននៅមហាវិទ្យាល័យ/ប្រកបមុខរបរត្រឹមត្រូវ ។

សូមចំណាំថា គម្រោងការណ៍ LCAP គឺរៀបចំឡើងសំរាប់តែគ្រប់គ្រងលើជំនួយមកពី Supplemental និង Concentration Grants ប៉ុណ្ណោះតាមរយៈប្រើរូបមន្តថ្មីសំរាប់ចាត់ចែងថវិការប្រចាំតំបន់ ។ ជំនួយថវិការទាំង ពីរ មុខនេះពិតជាមានចំនួនច្រើនជាងគេមែនសំរាប់ប្រើនៅក្នុងក្រសួងអប់រំ ឌីស្រ្ទីគ LBUSD, ប៉ុន្តែ … វាគ្មានអ្វីទាក់ទងទេជាមួយថវិការមកពីរដ្ឋាភិបាលសហព័ន្ធ ដូចជា: Title I និង អ្វីផ្សេង ។ ទៅតាមកាលៈទេសៈខ្លះ គឺគម្រោងការណ៍ LCAP នឹងធ្វើការយោងតាមជំនួយថវិការផ្សេងៗទាំងអស់នេះ ដើម្បីធ្វើឲ្យបុគ្គលទាំងអស់ ដែលមានមុខងារក្នុងកម្មវិធីសិក្សា អាចយល់អំពីគោលដៅទូទៅនៅក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ។

**សិស្សរៀនភាសា អង់គ្លេស – English Learners (ELs)**

គម្រោងការណ៍ LCAP រក្សាទុកចំនួនលុយ 1.1 លាន ដុល្លារ រៀងរាល់ឆ្នាំសំរាប់ជួយសិស្សរៀនភាសា អង់គ្លេស ។ ការរក្សាទុកនេះនឹងផ្តល់ជំនួយសំរាប់ការសរសេរ/និយាយបកប្រែភាសា, ការស្ទង់វាស់សមត្ថភាពប្រើភាសាតាមរយៈ California English Language Development Test (CELDT), ការរួមចំណែកពីមាតាបិតា, ជំនួយទូទៅសំរាប់សាលារៀន និង អ្វីផ្សេងជាច្រើនមុខទៀត ។

បន្ថែមទៅទៀត គឺគម្រោងការណ៍ LCAP រៀបចំកម្មវិធីផ្សេងៗទៀតសំរាប់ជួយនៅតាមសាលារៀនទាំងឡាយណា ដែលត្រូវការជំនួយ "ខ្លាំងជាងគេ" ដូចជា: ថ្នាក់បង្ហាត់អក្សរ, ការអប់រំលើកទឹកចិត្ត, ការទាក់ទងពន្យល់សិស្សអំពីសារសំខាន់នៃការចុះឈ្មោះយកថ្នាក់កម្រិតខ្ពស់ Advanced Placement (AP), កម្មវិធីសិក្សាបណ្ណាល័យ, ការជួលអ្នកចិត្តសាស្រ្តមកធ្វើការជាមួយសិស្ស, ការផ្តល់ជំនួយអន្តរាគមន៍ និង ការផ្តល់ឱកាសធ្វើជាអ្នកដឹកនាំ សំរាប់សិស្សជាជនជាតិភាគតិច ។ សិស្សរៀនភាសា អង់គ្លេស គឺជាចំណោមសិស្ស ដែលនឹងបានទទួលផលច្រើនជាងគេមកពីជំនួយទាំងអស់នេះ ។ តទៅនេះ គឺជាការលើកបង្ហាញ …

ក្នុងចំណោមសិស្សរៀនភាសា អង់គ្លេស 16,802 នាក់នៅក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ទាំងមូល គឺមាន 11,091 នាក់រៀននៅតាមកម្រិតសាលាបឋមសិក្សា/K-8 និង មាន 10,247 នាក់កំពុងរៀននៅក្នុងសាលា ដែលត្រូវការជំនួយខ្លាំងជាងគេ ។ នេះមានន័យថា សិស្សរៀនភាសា អង់គ្លេស គឺមានចំនួន 39% ក្នុងចំណោមសិស្សកំពុងរៀននៅតាមសាលាបឋមសិក្សា/K-8 ទាំងឡាយណា ដែលត្រូវការជំនួយខ្លាំងជាងគេ ។ បើយើងគិតលេខភាគរយនេះទៅចំនួនលុយ 3.3 លាន ដុល្លារ សំរាប់បើកកម្មវិធីបង្ហាត់អក្សរនៅតាមថ្នាក់ក្នុងឆ្នាំសិក្សា 2014-15 គឺយើងអាចដឹងថា ចំនួនលុយ 1.5 លាន ដុល្លារ បន្ថែមនឹងត្រូវប្រើសំរាប់ជួយសិស្សរៀនភាសា អង់គ្លេស ។ ចំណែកជំនួយផ្សេងៗទៀត ក៏មិនខុសគ្នាប៉ុន្មានទេ ។

លើសពីគម្រោងការណ៍ LCAP ទៅទៀត ក៏ក្រសួងអប់រំ ឌីស្រ្ទីគ នៅមានជំនួយបន្ថែមផ្សេងៗសំរាប់ជួយសិស្សរៀនភាសា អង់គ្លេស ។ ឧទាហរណ៍ … នៅឆ្នាំសិក្សា 2014-15 គឺគ្រូបង្រៀនឯកទេសសំរាប់សិស្ស EL នឹងទទួលមុខងារជួយសិស្សជាក្រុមជម្រើសនៅតាមកម្រិតសាលាមធ្យមសិក្សា ឬ ខ្ពស់ទៅ ។ មុខងាររបស់ពួកគាត់ គឺផ្តល់ជំនួយផ្នែកបង្ហាត់មេរៀនបន្ថែម និង ផ្តល់ជំនួយអន្តរាគមន៍បន្ថែម ។ នៅតាមសាលារៀននិមួយៗក៏នឹងមានគ្រូបង្រៀនពិសេសផ្សេងៗទៀតផង ដើម្បីជួយបង្ហាត់មេរៀនទៅកាន់សិស្ស EL ទាំងឡាយណា ដែលកំពុងជួបប្រទះការពិបាក ។

សំខាន់ជាងគេ … ក្នុងនាមមួយចំណែកនៃការប្រើតាមមេរៀនបង្ហាត់ស្រដៀងគ្នា (Common Core implementation) គឺក្រសួងអប់រំ ឌីស្រ្ទីគ LBUSD នឹងធ្វើការបត់បែនមេរៀនបង្ហាត់សំរាប់សិស្សរៀនភាសា អង់គ្លេស ។ ការបត់បែននេះនឹងរាប់បញ្ចូលផងអំពីការហាត់និយាយភាសាដែលស្របតាមខ្នាតគំរូថ្មីសំរាប់មេរៀនបណ្តុះភាសា អង់គ្លេស (English Language Development – ELD), កម្មវិធីហ្វឹកហ្វឺនសំរាប់គ្រូបង្រៀនស្តីអំពីការរាប់បញ្ចូលមេរៀន ELD ទៅជាមួយការបង្ហាត់មេរៀនប្រចាំថ្ងៃផ្នែកភាសា និង ការចាត់តាំងបុគ្គលិក EL ជាអ្នកកណ្តាលសំរាប់ផ្តល់ជំនួយដឹកនាំបង្ហាត់មេរៀនទៅកាន់សាលារៀនទាំងអស់ ។ ដូចស្របតាមគោលច្បាប់ផ្សេងៗទៀតដែរ គឺគោលដៅនៃក្រសួងអប់រំ ឌីស្រ្ទីគ LBUSD ត្រូវបានរៀបចំឡើងសំរាប់បង្កើតប្រព័ន្ធងាយយល់ ដែលផ្តល់ជំនួយដោះស្រាយទៅកាន់សេចក្តីត្រូវការពិសេសរបស់សិស្ស ។

**ជំនួយអប់រំសំរាប់សិស្ស – Counseling Services**

ក្រសួងអប់រំ ឱស្រ្ទីគ LBUSD មានគម្រោងការណ៍ពង្រីកជំនួយអប់រំលើកទឹកចិត្តសិស្ស និង ការអប់រំពន្យល់សិស្សអំពីសារសំខាន់ក្នុងការរៀនយកថ្នាក់ Advanced Placement (AP) ដែលបម្រុងពួកគេទៅរៀននៅមហាវិទ្យាល័យ ។ ជំនួយអប់រំលើកទឹកចិត្តសិស្សនឹងបើកសំដៅជួយនៅតាមសាលាបឋមសិក្សា/K-8 ទាំងឡាយណា ដែលត្រូវការខ្លាំងជាងគេ នៅឆ្នាំសិក្សា 2014-15 និង បន្ទាប់ទៅ គឺវាយបន្តទៅកាន់សាលាបឋមសិក្សា, K-8 និង សាលាមធ្យមសិក្សាផ្សេងៗនៅឆ្នាំសិក្សា 2015-16 និង ជាបន្តទៅទៀតនៅឆ្នាំសិក្សា 2016-17 តាមសេចក្តីត្រូវការមុនគេសំរាប់សិស្ស ដែលមិនទាន់បានដោះស្រាយគ្រប់គ្រាន់ ។ ការអប់រំពន្យល់សិស្សអំពីសារសំខាន់ក្នុងការរៀនយកថ្នាក់ AP គឺនឹងសំដៅជួយសិស្សជាជនជាតិភាគតិច ដែលរាប់បញ្ចូលផងជាសិស្សមកពីក្រុមគ្រួសារមានប្រាក់ចំណូលតិច, សិស្សរៀនភាសា អង់គ្លេស, សិស្សទទួលការចាត់ទុកឡើងវិញជាសិស្សមានសមត្ថភាពប្រើភាសា អង់គ្លេស ស្ទាត់ និង សិស្ស ដែលត្រូវបានមនុស្សធំផ្សេងជ្រើសយកចិញ្ចឹម ។

បន្ថែមទៅទៀត គឺក្រសួងអប់រំ ឱស្រ្ទីគ LBUSD មានគម្រោងការណ៍ធ្វើកិច្ចការរួមសាកលវិទ្យាល័យ University of Southern California - (USC) ។ សាកលវិទ្យាល័យ USC នឹងមានក្រុមផ្តល់ឱវាទសំរាប់ជួយអប់រំពន្យល់សិស្សជាជនជាតិភាគតិចនៅតាមសាលារៀន High School ដូចជា: សិស្សមកពីក្រុមគ្រួសារមានប្រាក់ចំណូលតិច, សិស្សរៀនភាសា អង់គ្លេស, សិស្សទទួលការចាត់ទុកឡើងវិញជាសិស្សមានសមត្ថភាពប្រើភាសា អង់គ្លេស ស្ទាត់ និង សិស្ស ដែលត្រូវបានមនុស្សធំផ្សេងជ្រើសយកចិញ្ចឹម ដើម្បីបង្កើនចំនួនពួកគេទៅរៀននៅមហាវិទ្យាល័យ និង ទទួលសញ្ញាប័ត្រជោគជ័យ ។ ក្រុមផ្តល់ឱវាទនឹងអប់រំពន្យល់អំពីរបៀបចុះឈ្មោះចូលរៀន និង បំពេញក្រដាសដាក់ពាក្យសុំជំនួយលុយបង់ថ្លៃសាលារៀនជូនក្រុមគ្រួសារជាម្នាក់–ទល់–ម្នាក់ និង ជាក្រុមទាំងមូល ។

តាមរយៈគម្រោងការណ៍ LCAP តែមួយប៉ុណ្ណោះ គឺការចំណាយថវិការសំរាប់ជំនួយអប់រំសិស្ស និង ការពន្យល់អំពីថ្នាក់ AP នឹងប្រើចំនួនលុយកាន់តែច្រើនពី 4.4 លាន ដុល្លារ នៅឆ្នាំសិក្សា 2014-15 ទៅដល់ 5.8 លាន ដុល្លារ នៅឆ្នាំសិក្សា 2016-17 ។ លើសពីជំនួយនៅក្នុងគម្រោងការណ៍ LCAP ទៅទៀត គឺជំនួយផ្សេងៗរបស់ក្រសួងអប់រំ ឱស្រ្ទីគ និង សាលារៀន (ដូចជា: Title I, Title III ... /ល/) រួមទាំងក្រសួងផ្សេងៗជាដៃគូផង នឹងបើកការពង្រីកបន្ថែម ដែលស្របតាមអនុសាសន៍នៃក្រុមប្រឹក្សា LCAP ។

**ទំនាក់ទំនងជាមួយមាតាបិតា – Parent Engagement**

គម្រោងការណ៍ LCAP រក្សាទុកចំនួនលុយ $350,000 រៀងរាល់ឆ្នាំសំរាប់បង្កើតកម្មវិធីបន្ថែម ដើម្បីទាក់ទាញការរួមចំណែកពីមាតាបិតានៅតាមសាលារៀន ដែលគ្មានជំនួយ Title I – (non-Title I schools) ។ ការរក្សាទុកចំនួនលុយនេះ គឺជាចំណុចបង្ហាញការស្មើភាពគ្នានៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ ជាមួយសាលារៀន Title I ដែលទទួលជំនួយប្រហែល $700,000 សំរាប់ការរួមចំណែកពីមាតាបិតានៅឆ្នាំសិក្សា 2014-15 ។ តាមរយៈប្រើជំនួយថវិការតែ ពីរ ប្រភពនេះប៉ុណ្ណោះ គឺក្រសួងអប់រំ ឱស្រ្ទីគ LBUSD មានគម្រោងការណ៍ចំណាយលុយលើសជាង មួយ លាន ដុល្លារ សំរាប់គាំទ្រមកលើក្រុមគ្រួសារនៃសិស្ស ។ ការប្រឹងប្រែងនេះនឹងចែកផ្តល់ជំនួយតាមរយៈ Parent University នៃក្រសួងអប់រំ ឱស្រ្ទីគ (ដើម្បីបង្ហាញពត៍មានជូនសាធារណៈជនសំរាប់បង្កើតជាទំនាក់ទំនង), កម្មវិធីក្រៅរួមគ្នាផ្សេងៗ ដែលមានក្រសួងសិក្សាកម្រិតខ្ពស់មកជួយអប់រំបង្ហាញក្រុមគ្រួសារអំពីរបៀបបម្រុងសិស្សទៅរៀននៅមហាវិទ្យាល័យ និង ការបង្កើតទំនាក់ទំនងតាម SchoolLoop, SchoolMessenger, ParentVUE និង អ្វីផ្សេងៗទៀត ដើម្បីពង្រឹងការឆ្លងឆ្លើយគ្នារវាងសាលារៀន និង ផ្ទះ ។

យោងតាមអនុសាសន៍នៃក្រុមប្រឹក្សា LCAP គឺទំនាក់ទំនងជាមួយមាតាបិតានឹងមានគោលដៅរៀបចំឡើងតាមរយៈប្រើច្រើនចំណែក ដូចជា: កម្មវិធីប្រជុំផ្តល់ពត៍មាននៅតាមសាលារៀន, ទំនាក់ទំនង online, ការចែកផ្តល់ពត៍មាននៅតាមក្រដាស និង ការជួបទាក់ទងគ្នាផ្ទាល់ ។ ការប្រើភាសាផ្សេងៗ ក្រៅពីភាសា អង់គ្លេស ក៏បានលើកដោះស្រាយផង ។

ដើម្បីបញ្ជាក់អំពីការប្រឹងប្រែងធ្វើពីក្រសួងអប់រំ ឱស្រ្ទីគ នៅក្នុងចំណុចនេះ គឺក្រុមប្រឹក្សា LCAP បានបង្កើតគោលដៅសំរាប់បង្កើនចំនួនភាគរយនៃមាតាបិតា ដែលបង្ហាញការពេញចិត្តមកលើឱកាសសំរាប់ពួកគាត់ចូលរួមចំណែកចាត់ចែងកម្មវិធី និង ការសម្រេចផ្សេងៗ ។ ភាពលូតលាស់រៀងរាល់ឆ្នាំ គឺនឹងសង្ឃឹមកើតឡើង ។ បន្ថែមទៅទៀត គឺក្រសួងអប់រំ ឱស្រ្ទីគ នឹងប្រើរង្វាស់កត់ទុកអំពីចំនួនផ្សេងៗទាក់ទងការរួមចំណែកពីមាតាបិតា ។

## ការរៀបចំទម្លាប់ និង ទំនាក់ទំនងល្អរវាងគ្នានៅក្នុងសាលារៀន – Positive School Culture and Climate

ក្រៅពីសញ្ញាបញ្ជាក់ភាពលូតលាស់ផ្នែកសិក្សា គឺនៅក្នុងគម្រោងការណ៍ LCAP មានការរៀបរាប់គោលដៅសំរាប់បង្កើនភាពសន្តិសុខ និង ទំនាក់ទំនងរវាងគ្នានៅក្នុងសាលារៀន តាមរយៈទទួលចម្លើយពីការស្ទង់មតិដោយសិស្ស, មាតាបិតា និង បុគ្គលិកសាលារៀន, ក្រោមការលើកលែងពីច្បាប់ No Child Left Behind waiver ។ រង្វាស់យ៉ាងងាយយល់នេះ គឺសង្កត់មកលើ ប្រាំបី ចំណុចសំខាន់ជាងគេដូចតទៅ ...

- ចំណេះយល់ដឹង និង ភាពយុត្តិធម៌អំពីការអប់រំ/បំពត់, វិន័យ និង ទម្លាប់ទូទៅ
- ភាពកក់ក្តៅផ្នែករាប់អានគ្នា/ជម្រៅទឹកចិត្ត
- ទំនាក់ទំនងស្របគ្នារវាងសាលារៀន/សហគមន៍
- ជំនួយគាំទ្រមកលើការសិក្សា
- ជំនួយគាំទ្រសំរាប់ការរាប់អានគ្នា/ជម្រៅទឹកចិត្ត
- ជំនួយគាំទ្រទូទៅ
- ការទទួលស្គាល់តម្លៃរបស់ខ្លួនជាមនុស្សម្នាក់នៅក្នុងចំណោមក្រុម
- ការទទួលស្គាល/គោរពចំពោះប្រពៃណីខុសប្លែកពីគ្នា

ភ្ជាប់ជាមួយចម្លើយមកពីការស្ទង់មតិវិញ គឺគម្រោងការណ៍ LCAP មានការរៀបចំគោលដៅសំរាប់តាមដានអំពីវត្តមានប្រចាំថ្ងៃនៅក្នុងសាលារៀន, ចំនួនសិស្ស ដែលទទួលការឃាត់ឃាំងចូលថ្នាក់, ចំនួនសិស្ស ដែលទទួលការបណ្តេញចោលពីសាលារៀន និង ចំនួនសិស្ស ដែលបញ្ចប់ការសិក្សាពេញច្បាប់ពី High School – ចំណុចទាំងអស់នេះ គឺបញ្ជាក់អំពីសារសំខាន់ ដែលប៉ះពាល់មកលើទំនាក់ទំនងជាមួយសិស្ស ។ គោលដៅសំខាន់ គឺរក្សាភាពសន្តិសុខ និង ឱកាសល្អសំរាប់សិស្សទាំងអស់ទទួលការសិក្សាស្មើភាពគ្នា ដោយគ្មានជ្រេទៅកាន់ក្រុមណាមួយ ។

ដើម្បីបង្កើតគោលដៅទាំងអស់នេះបាន គឺក្រុមប្រឹក្សា LCAP សូមលើកបង្ហាញអនុសាសន៍ខ្លះៗដូចតទៅ ដែលគួរសំគាល់ទុក ...

- ពង្រីកកម្មវិធីអប់រំ, ការតាមពិនិត្យ និង ការចែកផ្តល់ជំនួយផ្សេងៗ ដែលដោះស្រាយផ្ទាល់មកលើសេចក្តីត្រូវការរបស់សិស្ស ។

- ផ្តល់ជំនួយគាំទ្រទៅកាន់គ្រូបង្រៀន ដើម្បីជួយពួកគាត់ឲ្យមានសមត្ថភាពបង្កើនការបង្ហាត់ ដែលទីបំផុត គឺមានទំនាក់ទំនងល្អជាមួយសិស្ស ។

- ជួលគ្រូបង្រៀនបន្ថែម រួមទាំងបុគ្គលិកផ្សេងៗ ដូចជា: អ្នកផ្តល់ឱវាទ, អ្នកចិត្តសាស្ត្រ និង អនុនាយកសាលា ដើម្បីបន្ថយចំនួនសិស្សរៀននៅតាមថ្នាក់ និង ផ្តល់ជំនួយអប់រំកាន់តែច្រើនទៅកាន់សិស្ស ។

នៅក្នុង Section 3B នៃគម្រោងការណ៍ LCAP គឺមានការលើកដោះស្រាយអំពីអនុសាសន៍ទាំងអស់នេះ ។ វារៀបរាប់អំពីការបើកពង្រីកថ្នាក់បង្ហាត់អក្សរ, ជំនួយអប់រំលើកទឹកចិត្ត, ជំនួយអប់រំពន្យល់អំពីសារសំខាន់នៃការចុះឈ្មោះយកថ្នាក់ Advanced Placement សំរាប់ទៅរៀននៅមហាវិទ្យាល័យ, ជំនួយព្យាបាលជម្ងឺសំរាប់សិស្ស, កម្មវិធីសិក្សាបណ្ណាល័យ, អ្នកចិត្តសាស្ត្រធ្វើការជាមួយសិស្ស និង កម្មវិធីផ្សេងៗ ដែលសំដៅមកលើសាលារៀនទាំងឡាយណា ដែលត្រូវការជំនួយខ្លាំងជាងគេ ។

បន្ថែមទៅទៀត គឺគម្រោងការណ៍ LCAP ជួយបង្កើនកម្មវិធី ដែលសង្កត់មកលើការផ្តល់ជំនួយអន្តរាគមន៍ និង ឱកាសដឹកនាំសំរាប់សិស្សមានសមត្ថភាព ដែលភាគច្រើនជាសិស្សជនជាតិភាគតិច ។

ចំនួនលុយ $500,000 ត្រូវបានរក្សាទុកសំរាប់ប្រើមកលើ Male/Female Academy និង កម្មវិធីហ្វឹកហ្វឺនផ្នែកប្រើអំពើយុត្តិធម៌ ។ ជំនួយទាំងអស់នេះជម្រុញឲ្យមានការដោះស្រាយរវាងគ្នាតាមសម្រួល, ទទួលស្គាល់ប្រពៃណីរវាងគ្នាទៅវិញទៅមក, រាប់អានគ្នាទៅវិញទៅមក និង ការប្រើអំពើអប់រំ/បំពត់ផ្សេងជំនួសការឃាត់ឃាំងសិស្សចូលថ្នាក់ និង ការបណ្តេញសិស្សចោលពីសាលារៀន ។

ក្រៅពីគម្រោងការណ៍ LCAP គឺក្រសួងអប់រំ ឱស្រ្ទីត បានបង្កើតច្បាប់ផ្សេងៗទៀតផងសំរាប់បង្កើនភាពសន្តិសុខ និង ការរាប់អានគ្នានៅក្នុងសាលារៀន ។ អ្វីគួរសំគាល់ គឺ “Safe and Civil Schools” ដែលប្រើកម្មវិធីតាមការស្រាវជ្រាវយ៉ាងស័ក្តិសិទ្ធិសំរាប់អប់រំសិស្សឲ្យកាន់ភ្ជាប់នូវអាកប្បកិរិយាល្អ ។ សាលាបឋមសិក្សា, K-8 និង មធ្យមសិក្សាទាំងអស់ (រួមទាំងសាលារៀន High School ខ្លះផង) បានបញ្ជូនបុគ្គលិកចូលរួមហ្វឹកហ្វឺន ដើម្បីបង្កើតកម្មវិធីនេះនៅតាមសាលារៀនរៀងៗខ្លួន ដោយមានក្រសួងអប់រំ ឱស្រ្ទីត តាមផ្តល់ជំនួយជាបន្តបន្ទាប់បន្ថែមស្តីអំពី …

- ការបង្កើតប្រព័ន្ធសំរាប់ដោះស្រាយបញ្ហាអប់រំ/បំពត់
- សេចក្តីត្រូវការទូទៅរបស់សិស្ស
- ទំនាក់ទំនងល្អនៅក្នុងសាលារៀន

ការប្រឹងប្រែងរួមគ្នានេះឯង ដែលបណ្តាលឲ្យក្រសួងអប់រំ ឱស្រ្ទីត LBUSD ជាប់ឈ្មោះទទួលរង្វាន់ពិសេសមួយហៅ Golden Bell Award ។